ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៦

ជំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត
មុខតំណែង៖ អ្នកស្ម័គ្រចិត្តត្រួតពិនិត្យចម្រោះទឹកស្អាតនិងអនាម័យសាលារៀន

អង្គការស្អាតកម្ពុជា ជាអង្គការគ្រិស្តបរិស័ទក្នុងស្រុកមួយ ដែលបាន និងកំពុងអនុវត្តគម្រោងក្រោមគោលបំណងទឹកស្អាត និងអនាម័យ (WASH)។ បេសកកម្មគឺ ដើម្បីលើកកំពស់គុណភាពទឹក អនាម័យ សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាសហគមន៍គោលដៅដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។ ការងារទាំងអស់ត្រូវបានធ្វើឡើងដោយសហការជាមួយថ្នាក់ដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អង្គការស្អាតកម្ពុជាបច្ចុប្បន្នកំពុងអនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តចំនួន ១១ ដូចជា ខេត្តបាត់ដំបង ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ សៀមរាប ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ និងរតនគីរី។

អង្គការស្អាតកម្ពុជា ត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តរយៈពេលវែងចំនួន **១នាក់** សម្រាប់មុខតំណែងជា **អ្នកស្ម័គ្រចិត្តត្រួតពិនិត្យចម្រោះទឹកស្អាតនិងអនាម័យសាលារៀន** ដែលមានទីតាំងនៅ **ភូមិជ្រៃផ្សារ ឃុំជ្រៃ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។**

១. ការទទួលខុសត្រូវក្នុងការងារ ៖

- ប្រមូលព័ត៌មានចំរោះសាលារៀនមុនៗ (Functionality)
- រៀបចំសំភារៈ/ឧបករណ៍ (small tools) និងកំណត់ផែនការ ដើម្បីធ្វើការត្រួតពិនិត្យចំរោះ
- ធ្វើការតំឡើងចំរោះឡើងបើសិនជាចាំបាច់
- ត្រួតពិនិត្យបរិក្ខារចំរោះ (WASH) និងថតរូប
- ចូលរួមការត្រួតពិនិត្យចំរោះជាមួយអ្នកស្ម័គ្រក្នុងសហគមន៍ -សាលារៀន(ប្រសិនបើមាន)។
- ជំរុញនិងលើកទឹកចិត្តដល់នាយកសាលា -គ្រូបង្រៀន-
  សិស្សានុសិស្សអោយប្រើប្រាស់និងថែចំរោះទឹកអោយបានត្រឹមត្រូវ។
- បង្រៀនអំពីការប្រើប្រាស់ និង ថែទាំចំរោះដល់ នាយកសាលា-គ្រូបង្រៀន-
- សិស្សានុសិស្សក្នុងកំឡុងពេលនិងក្រោយត្រួតពិនិត្យចំរោះទឹកតាមសាលារៀនគោលដៅ។
- ជួយសំរបសំរួលអ្នកដឹកជញ្ជូនសំភារៈតំឡើងចំរោះធំពីការិយាល័យខេត្តកំពង់ស្ពឺទៅកាន់សាលារៀនគោលដៅ
- ដើម្បី ទុកដាក់និង តំឡើងចំរោះទឹក។
- ជួយសំរួលក្នុងការតំឡើងចំរោះទឹកក្នុងសាលារៀនតាមតំបន់គោលដៅ។
- ជួយសំរួលក្នុងការពិនិត្យ មើលនូវតំរូវការនៃការស្នើសុំខ្សាច់ពីគំរោងតាមខេត្តផ្សេងៗអោយបានទាន់ពេលវេលា។
- បង្រៀនដល់នាយកសាលា-គ្រូបង្រៀន-សិស្សានុសិស្ស នូវរបៀបលាងខ្សាច់ និងត្រួតពិនិត្យ (តំឡើងជាថ្មី)។
- តំលើងចំរោះជូន នាយកសាលា-គ្រូបង្រៀន- សិស្សានុសិស្ស ដែលប្រកបទៅដោយគុណភាព។
- បង្រៀនឡើងវិញដល់ គ្រូបង្រៀន-សិស្សានុសិស្ស នូវរបៀបថែទាំចំរោះ ការប្រើប្រាស់ នៅពេលដែល
- តំឡើងចំរោះនៅតាម សាលារៀននីមួយៗ។

- មានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានភូមិ/ឃុំ មន្ត្រីអភិវឌ្ឍន៍ភូមិ និង នាយកសាលា-គ្រូបង្រៀននិង
- សិស្សានុសិស្សតាមសាលារៀនគោលដៅ។
- មានទំនាក់ទំនងល្អជាមួយក្រុមការងារ។
- សហប្រតិបត្តការត្រួតពិនិត្យចំរោះនៅតាមសាលារៀនគោលដៅរួមជាមួយសិស្សានុសិស្សនិង បុគ្គលិកអប់រំសុខភាពនិងអនាម័យសាលារៀននិមួយៗ។
- ភារៈកិច្ចផ្សេងៗដែលតំរូវដោយអ្នកគ្រប់គ្រងនិងក្រុមការងារ។

២. **លក្ខខណ្ឌនៃការជ្រើសរើស ៖**

- ធ្លាប់ធ្វើការជាមួយសហគមន៍កាន់តែប្រសើរ។
- អាន និយាយ និង សរសេរភាសាខ្មែរបានល្អ។
- ជំនាញបច្ចេកទេស។
- មានសមត្ថភាពក្នុងការសំរបសំរួលសហគមន៍។
- ធ្វើការងារដោយឯករាជម្ចាស់ការ និង មានគំនិតច្នៃប្រឌិត។
- មានសមត្ថភាពបង្រៀន-ពន្យល់ដល់សហគមន៍ អំពីការថែទាំ និងការប្រើប្រាស់ចំរោះដល់សិស្សានុសិស្សនៅក្នុងសាលារៀនគោលដៅ។
- សរសេរបាយការណ៍។
- ដឹងច្បាស់អំពីភូមិសាស្ត្រក្នុងតំបន់ប្រតិបត្តិការ។
- មានចំណេះដឹងក្នុងការប្រើប្រាស់និងបើកបររថយន្តបានកាន់តែប្រសើរ។
- ប្តេជ្ញាគោរពតាមបេសកកម្ម និង គុណតំលៃរបស់អង្គការ។
- ធ្វើការងារជាក្រុម។
- ចេះបត់បែន។
- មានឆន្ទៈក្នុងការធ្វើការងារជាមួយសហគមន៍។

ចំពោះបេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ជាមួយមុខតំណែងនេះ សូមមកទទួលយកពាក្យសុំធ្វើការងារនៅការិយាល័យ ខេត្ត **ព្រៃវែង** ឬអាចទាញយកពាក្យសុំបម្រើការងារជាភាសា ខ្មែរ ឬ អង់គ្លេស ទៅបំពេញ ហើយបញ្ជូនមកវិញដោយភ្ជាប់ជាមួយប្រវត្តិរូបសង្ខេប (CV & Cover Letter) រួចបញ្ជូនមកកាន់ការិយាល័យ **ព្រៃវែង** តាមរយៈអាសយដ្ឋាន**ខាងលើ** ឬទំនាក់ទំនងទូរស័ព្ទលេខ: (**៨៨៥**)-**២៣ ៨៨០ ១៦៤**, Email: hr@clearcambodia.org, Website: www.clearcambodia.org.

<u>សំគាល់:</u> សូមភ្ជាប់មកជាមួយនូវឯកសារថតចំលង អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ និង ឯកសារពាក់ព័ន្ធផ្សេងទៀត និង រូបថត ៤X៦ ចំនួន ២សន្លឹក។

<u>បន្ទាប់ពីពិនិត្យលើសំណុំបែបបទសុំបំរើការងារអ្នកជាប់បញ្ជីសម្រាំងនិងត្រូវបានធ្វើការទំនាក់ទំនង</u> ដើម្បីធ្វើការសម្ភាសន៍។

ថ្ងៃផុតកំណត់ទទួលពាក្យនៅ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៦៕